# ស្ថានទូតអូស្ត្រាលី
# រាជធានីភ្នំពេញ

## សេចក្តីប្រកាសព័ត៌មាន

### គំរោងស្តារឡើងវិញផ្លូវដែកកម្ពុជា និងការត្រួតពិនិត្យលើភាពអនុលោម របស់ធនាគារអភិវឌ្ឍន៍អាស៊ី

ប្រទេសអូស្ត្រាលីសូមស្វាគមន៍ចំពោះរបាយការណ៍របស់គណៈកម្មាធិការពិនិត្យលើភាពអនុលោមនៃធនាគារអភិវឌ្ឍន៍អាស៊ី ដែលជាការវាយតំលៃដ៏មានសារៈប្រយោជន៍មួយសំរាប់គ្រួសារទាំងឡាយដែលទទួលរងនូវផលប៉ះពាល់ ដោយគំរោងស្តារឡើងវិញផ្លូវដែកកម្ពុជា។

ក្រុមប្រឹក្សាភិបាលរបស់ធានាគារអភិវឌ្ឍន៍អាស៊ី បានជួបប្រជុំគ្នាដើម្បីពិចារណាលើរបាយការណ៍របស់គណៈកម្មាធិការពិនិត្យលើភាពអនុលោម និង អនុសាសន៍ផ្សេងៗស្តីពីគំរោងស្តារឡើងវិញផ្លូវដែកកម្ពុជា កាលពីថ្ងៃទី៣១ ខែមករា កន្លងមក។

ក្រុមប្រឹក្សាភិបាលបានឯកភាពគ្នាលើកយកគំរោងនេះទៅអនុវត្តអោយបានពេញលេញតាមគោលការណ៍ស្តីពីការការពារផលប៉ះពាល់សង្គម និង បរិស្ថាន ហើយរដ្ឋាភិបាលអូស្ត្រាលីគាំទ្រសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលនេះ។

ប្រទេសអូស្ត្រាលីបានផ្តល់ការគាំទ្រយ៉ាងពេញទំហឹងចំពោះប្រជាជនដែលរងនូវផលប៉ះពាល់ដោយគំរោងស្តាឡើងវិញផ្លូវដែកកម្ពុជា។ យើងខ្ញុំនឹងធ្វើការងារប្រកបដោយផលប្រយោជន៍ជាមួយដៃគូរការងារនានាដែលទទួលខុសត្រូវក្នុងការអនុវត្តន៍អនុសាសន៍នៅក្នុងរបាយការណ៍នេះ៕

**សំរាប់ពត៌មានបន្ថែមសូមទាក់ទង:**
លោក **សាយម៉ុន ហ្វែលឡូ** (Mr Simon Fellows) អនុប្រធានបេសកកម្ម
**ស្ថានទូតអូស្ត្រាលី ភ្នំពេញ**
ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១៤